**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

Kingdom of Wonder

feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០៤៦ ទស.ឃល.អរទ

ថ្ងៃ ចន្ទ ៤ រោច ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២២

# សេចក្តីជូនដំណឹង

## ស្តីពីការទទួលរៀបចំវេទិកាទេសចរណ៍អាស៊ានឆ្នាំ២០២២ (ATF 2022) នៅរាជធានីភ្នំពេញ ក្រោមប្រធានបទ "អាស៊ាន៖ សហគមន៍សន្តិភាព និងវាសនាតែមួយ"

## "ASEAN – A Community of Peace and Shared Future"

ក្រសួងទេសចរណ៍ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា កម្ពុជានឹងទទួលធ្វើជាម្ចាស់ផ្ទះរៀបចំវេទិកាទេសចរណ៍អាស៊ានឆ្នាំ២០២២ (**ASEAN Tourism Forum-ATF 2022**) នៅរាជធានីភ្នំពេញ **ចាប់ពីថ្ងៃទី១៦-២២ ខែមករា ឆ្នាំ២០២២** ក្រោមប្រធានបទ **"អាស៊ាន៖ សហគមន៍សន្តិភាព និងវាសនាតែមួយ" (ASEAN – A Community of Peace and Shared Future)** ។

វេទិកាទេសចរណ៍អាស៊ានឆ្នាំ២០២២ មានព្រឹត្តិការណ៍សំខាន់ៗដូចជា កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទេសចរណ៍អាស៊ាន (ASEAN Tourism Ministers Meetings) កិច្ចប្រជុំស្ថាប័នជាតិទេសចរណ៍អាស៊ាន (ASEAN NTOs Meetings) និងកិច្ចប្រជុំពាក់ព័ន្ធ ព្រមទាំងកិច្ចប្រជុំផ្នែកឯកជន (ASEANTA Meetings) សិក្ខាសាលានានា និងព្រឹត្តិការណ៍ពិព័រណ៍ទេសចរណ៍អន្តរជាតិ TRAVEX។ ការតាំងពិព័រណ៍ទេសចរណ៍អន្តរជាតិ TRAVEX ជាវេទិកាធុរកិច្ចទេសចរណ៍ដ៏ធំបំផុតក្នុងអាស៊ាន ដែលនឹងប្រព្រឹត្តទៅចាប់ពី**ថ្ងៃទី១៨-២០ ខែមករា ឆ្នាំ២០២២** និងមានការចូលរួមពីក្រុមហ៊ុនជាអ្នកលក់ (Sellers) ប្រមាណជាង ៤៥០ក្រុមហ៊ុន ក្រុមហ៊ុនជាអ្នកទិញ (Buyers) ប្រមាណ ៤៥០ក្រុមហ៊ុន និងអ្នកសារព័ត៌មានជាតិ-អន្តរជាតិ ១០០រូប មកពីជុំវិញពិភពលោក។

ក្នុងន័យនេះ ក្រសួងទេសចរណ៍ សូមអញ្ជើញសាធារណជន ប្រតិបត្តិករទេសចរណ៍ ដៃគូអភិវឌ្ឍន៍ ផ្នែករដ្ឋ-ឯកជន ស្ថាប័នពាក់ព័ន្ធ សហគមន៍ទេសចរណ៍ អ្នកសារព័ត៌មាន មេត្តាជ្រាបជាព័ត៌មាន ចូលរួមសហការ និងផ្សព្វផ្សាយផលិតផលទេសចរណ៍ល្អៗរបស់យើងដល់អ្នកចូលរួមក្នុងវេទិកាទេសចរណ៍អាស៊ានខាងលើ ឱ្យបានទូលំទូលាយ ក៏ដូចជាចូលរួមស្តារវិស័យទេសចរណ៍ឡើងវិញក្រោយវិបត្តិកូវីដ-១៩ ។

ព័ត៌មានលម្អិត សូមទំនាក់ទំនងមកនាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេស នៃក្រសួងទេសចរណ៍តាមរយៈទូរស័ព្ទលេខ ០១៧ ៩៣៨ ៣៩៣ ឬអ៊ីម៉ែល prakvuthy1983@gmail.com, david.lim@mpinetwork.com ៕

ក្រសួងទេសចរណ៍

CS Scanned with CamScanner